**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង

## ស្តីពីការព្យួរកិច្ចសន្យាការងារជូនកម្មករនិយោជិត

ឆ្នាំពីរពាន់ម្ភៃបី ថ្ងៃទីម្ភៃប្រាំបួន ខែមិថុនា វេលាម៉ោងប្រាំបី និងសាមសិបនាទី នៅការិយាល័យក្រុមហ៊ុនតាកែវស៊ូ (ខេមបូឌា) ដែលមានទីតាំងស្ថិតនៅភូមិត្រាំ សង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ មានបើកកិច្ចប្រជុំរួមស្តីពីការព្យួរកិច្ចសន្យាការងារជូនកម្មករនិយោជិត ក្រោមអធិបតីភាពលោកស្រី CHEN CHUNXIA ជានាយកគ្រប់គ្រងរោងចក្រតាកែវស៊ូ (ខេមបូឌា) និងមានការចូលរួមពីអ្នកបកប្រែភាសាចិនខ្មែរ ផ្នែករដ្ឋបាល ផ្នែកគណនេយ្យ ផ្នែកសិទ្ធិមនុស្ស តំណាងសហជីពមូលដ្ឋាន ប្រតិភូបុគ្គលិក និងប្រធានផ្នែកសង្វាក់ផលិតកម្មគ្រប់ផ្នែកទាំងអស់ចំនួន15នាក់។

**ក/សមាសភាពចូលរួម** ៖ បញ្ជីវត្តមានជូនភ្ជាប់។

**ខ/របៀបវារៈ** ៖ ការព្យួរកិច្ចសន្យាការងារជូនកម្មករនិយោជិត

**គ/អំពីលទ្ធផលនៃអង្គប្រជុំ** ៖ ក្រោយពីមានការពិភាក្សាគ្នាយ៉ាងល្អិតល្អន់រួចមក ភាគីទាំងពីរបានឯកភាពគ្នា និងសម្រេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន១២៧នាក់ (ស្រី១១៩នាក់) ចាប់ពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣១ ខែកក្កដាឆ្នាំ២០២៣ មានលក្ខខណ្ឌដូចខាងក្រោម ៖

ចំណុចទី១ ៖ ក្នុងកំឡុងពេលព្យួរការងារ ចាប់ពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៣ ក្រុមហ៊ុននឹងផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតចំនួន ៣០ដុល្លា (សាមសិបដុល្លា) បើកប្រាក់នៅថ្ងៃទី១០ ខែសីហា ឆ្នាំ ២០២៣។

ចំណុចទី២ ៖ កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ នេះតទៅ រហូតដល់មានកិច្ចព្រមព្រៀងថ្មីទៀតមកជំនួស។

អង្គប្រជុំនេះបានចប់សព្វគ្រប់នៅវេលាម៉ោង១០ និង០៥នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ដោយក្តីសោមនស្សរីករាយក្រោមបរិយាកាសយោគយល់ និងអធ្យាស្រ័យគ្នាទៅវិញទៅមក។

ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣

បានឃើញ និងឯកភាព | អ្នកធ្វើកំណត់ហេតុ

**ប្រធានអង្គប្រជុំ** | **ហត្ថលេខា**

TAKEO SHOES (Cambodia) Co.,Ltd ផ្នែករដ្ឋបាល

陳春霞